# សន្និបាតលើកទី ១២

# របស់

# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា




## ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

# កំណត់ហេតុ
# អង្គសន្និបាតលើកទី១២ ប្រចាំឆ្នាំ២០២៣
# របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

## ១. សេចក្តីផ្តើម

ថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ៨:០០ ព្រឹក សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក) បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក្រសួង ឧវបន) និងលោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។ អង្គសន្និបាតក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង និងតំណាងមកពីក្រសួងអភិវឌ្ឍន៍ជនបទ ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ស្ថានទូតចក្រភពអង់គ្លេស អង្គការ Water.org កម្មវិធី CAPRED ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្រុមប្រឹក្សាភិបាលគណៈកម្មាធិការប្រតិបត្តិ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនផ្គត់ផ្គង់ផលិតផលនិងសេវាកម្ម និងសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សរុបចំនួន ៤១៥នាក់ (ស្រី ១១៥នាក់)។ ទន្ទឹមនឹងនោះក៏មានការតាំងបង្ហាញផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងវិស័យទឹកស្អាតផងដែរ។

## ២. គោលបំណង

អង្គសន្និបាតប្រចាំឆ្នាំលើកទី១២ ត្រូវបានរៀបចំឡើងក្នុងគោលបំណងៈ

- អបអរសាទរសមិទ្ធិផលរបស់ក្រុមប្រឹក្សាភិបាលសមាគមអាណត្តិដំបូងសម្រាប់សមាគមនីតិបុគ្គ ២០២០-២០២៣)
- ជ្រើសរើសក្រុមប្រឹក្សាភិបាលសមាគមអាណត្តិទី២ សម្រាប់សមាគមនីតិបុគ្គល (២០២៤-២០២៧)
- អបអរសោទរសមិទ្ធិផលរបស់សមាគម ឆ្នាំ២០២៣ និងផែនការប្រចាំឆ្នាំ២០២៤
- បង្កើនទំនាក់ទំនងជាមួយសមាជិកឱ្យកាន់តែប្រសើរឡើង និងចែករំលែកចំណេះដឹងនិងបច្ចេកវិទ្យាថ្មីៗ។

## ៣. របៀបវារៈ

កម្មវិធីលម្អិតនៃអង្គសន្និបាតប្រចាំឆ្នាំលើកទី១២នេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ១។

## ៤. លទ្ធផលនៃអង្គសន្និបាត

### ៤.១. កិច្ចស្វាគមន៍ និងសុន្ទរកថាបើកកម្មវិធីអង្គសន្និបាត

#### ក. មតិស្វាគមន៍អង្គសន្និបាត

លោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម ឡើងមានមតិស្វាគមន៍នូវអង្គសន្និបាត និងថ្លែងអំណរគុណដល់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧរបន អង្គទូត និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និបាតនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤នេះ។ លោក **ឡេង ខៀវ** ក៏បានគូសបញ្ជាក់ពីការចូលរួមរបស់សមាគម ក៏ដូចជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់អតិថិជន ប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។ ក្នុងនោះ ការផ្គត់ផ្គង់ទឹកស្អាតពីវិស័យឯកជនបានចូលរួមចំណែកក្នុងការផ្តល់សេវាទឹកស្អាតបានប្រមាណ ៥៣.៥៧% ដែលនេះជាការបង្ហាញភាពជាដៃគូរបស់ប្រតិតបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនជាមួយរាជរដ្ឋាភិបាល។ ឆ្លៀតក្នុងឱកាសនោះ លោកប្រធានក្រុមប្រឹក្សាភិបាល ក៏បានលើកជាសំណូមពរដល់ក្រសួងឧរបន បន្តជួយគាំទ្រសមាគម និងជួយកៀរគរប្រភពទុនវិនិយោគ សម្រាប់ជួយគាំទ្រដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដើម្បីពន្លឿន និងធានាភាពជោគជ័យក្នុងការលើកកម្ពស់វិស័យទឹកស្អាតនៅកម្ពុជា។

#### ខ. ចំណាប់អារម្មណ៍របស់អង្គការ Water.org

លោកស្រី **Gay Santos** នាយកតំបន់អាស៊ីអាគ្នេយ៍របស់អង្គការ **Water.org** បានឡើងថ្លែងនូវមតិចំណាប់អារម្មណ៍ក្នុងអង្គសន្និបាត ដោយបានអបអរសាទរដល់លទ្ធផលសម្រេចរបស់សមាគម ក្នុងឆ្នាំ២០២៣ ដែលនេះជាការគូសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរបស់សមាគម ក្នុងការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។ អង្គការ **Water.org** បានប្រតិបត្តិការងាររបស់ខ្លួនក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ២០១៥ ហើយបាននឹងកំពុងធ្វើការជាមួយសមាគម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្នុងការពង្រីកវិសាលភាពការទទួលបាននូវទឹកស្អាត និងអនាម័យដល់ប្រជាជន។ ជាលទ្ធផល ប្រជាជនកម្ពុជាប្រមាណ២លាននាក់ ទទួលបានទឹកដែលមានសុវត្ថិភាព និងអនាម័យតាមរយៈកម្មវិធីកម្ចីទឹកស្អាតរបស់ខ្លួន ដែលមានកម្ចីសរុបចំនួន ៤៦៣.០០០ ស្មើនឹងទំហំទឹកប្រាក់ ២៩៨ លានដុល្លារ។ លោកស្រីបានគូសបញ្ជាក់បន្ថែមថា អង្គការ **Water.org** បានអនុវត្តតួនាទីរបស់ខ្លួនស្របទៅនឹងទស្សនៈវិស័យ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៣-២០២៨) របស់រាជរដ្ឋាភិបាលក្នុងការកសាងមូលដ្ឋានគ្រឹះ ដើម្បីសម្រេចបាននូវគោលដៅប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៥០ ហើយវិស័យទឹកស្អាតត្រូវបានទទួលស្គាល់ជាវិស័យអាទិភាពមួយសម្រាប់ការពង្រឹងនូវភាពធន់ និងការប្រកួតប្រជែងសេដ្ឋកិច្ច និងការអភិវឌ្ឍទីប្រជុំជនប្រកបដោយចីរភាព។ ក្នុងនោះយុទ្ធសាស្ត្ររួមដើម្បីដោះស្រាយនូវបញ្ហាជាមូលដ្ឋាន និងពង្រីកជំនួយហិរញ្ញវត្ថុដល់វិស័យទឹកស្អាតរួមមានៈ ១) រៀបចំឱ្យមានអភិបាលកិច្ច ការពង្រឹងស្ថាប័ន គោលនយោបាយ ថ្លៃលក់ទឹក និងបទដ្ឋានគតិយុត្តិ ដើម្បីធាននានូវតម្លាភាព ស្ថិរភាព និងចីរភាព ២) ការគ្រប់គ្រងបច្ចេកទេស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពរបស់ប្រតិបត្តិករដើម្បីទទួលបាននូវទំនុកចិត្ត និង៣) បញ្ហាពាក់ព័ន្ធនឹងការវិនិយោគ និងហិរញ្ញប្បទានក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត។

### គ. ចំណាប់អារម្មណ៍របស់ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា

ឯកឧត្តម **Justin Whyatt** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា បានបង្ហាញនូវសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងសន្និបាតលើកទី១២ របស់សមាគម។ ក្នុងនោះ ឯកឧត្តម បានលើកឡើងពីសារៈសំខាន់នៃការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជន ក៏ដូចសហគមន៍ទាំងមូល ដែលវាបានជួយលើកកម្ពស់សុខភាពប្រជាជនឱ្យបានល្អ និងសេដ្ឋកិច្ចប្រសើរឡើង។ ឯកឧត្តម ក៏បានទទួលស្គាល់ និងកោតសសើរនូវតួនាទីរបស់ ក្រសួងឧវបន ក្នុងវិស័យទឹកស្អាត ដែលមានទាំងវិស័យឯកជន និងវិស័យសាធារណៈបានដើរតួនាទីយ៉ាងសំខាន់ក្នុងលើកកម្ពស់វិស័យទឹកស្អាត ដើម្បីជំរុញឱ្យសម្រេចបាននូវគោលដៅមនុស្សគ្រប់រូបទទួលបានទឹកស្អាតប្រើប្រាស់នៅឆ្នាំ២០៣០។ គោលដៅនេះ គឺពិតជាមានសារៈសំខាន់ និងមានមហិច្ឆតាខ្ពស់ ដូច្នេះដើម្បីសម្រេចបាននូវគោលដៅនេះ យើងត្រូវការពន្លឿន និងដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ប្រជាជនប្រមាណ៥០% នៅមិនទាន់ទទួលបានទឹកស្អាតប្រើប្រាស់
- ការផ្គត់ផ្គង់ទឹកស្អាតមានការបំបែកជាផ្នែកៗច្រើន ដែលនាំឱ្យការវិនិយោគមិនសូវមានគុណភាព និងប្រសិទ្ធភាព
- មានភាពចន្លោះប្រហោងធំលើហិរញ្ញប្បទានក្នុងវិស័យទឹកស្អាត ដែលទាមទារឱ្យមានការបំពេញបន្ថែម
- កែសម្រួលនូវលិខិតបទដ្ឋានគតិយុត្តិ ការសម្របសម្រួល ភាពជាតំណាងវិស័យឯកជន និងការប្រតិបត្តិរបស់ប្រតិបត្តិករ
- ការប្រែប្រួលអាកាសធាតុដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពទឹក និងគម្រាមកំហែងដល់ភាពជឿជាក់ និងចីរភាពនៃការផ្គត់ផ្គង់ទឹកស្អាត។

ឯកឧត្តម ក៏បានគូសបញ្ជាក់បន្ថែមថា ប្រទេសអូស្ត្រាលីគឺជាដៃគូរបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ និងដើម្បីសម្រេចបាននូវគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០៣០។ កន្លងមក ទូតអូស្ត្រាលី បានធ្វើការជាមួយក្រសួងឧវបន និងសមាគម ក្រោមកម្មវិធីវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ហើយនឹងបន្តកិច្ចសហប្រតិបត្តិការក្នុងការសម្រេចបាននូវគោលដៅទឹកស្អាតរបស់កម្ពុជាតាមរយៈកម្មវិធី **CAPRED** បន្តទៀត។

### ឃ. សុន្ទរកថាបើកអង្គសន្និបាតដោយ **ឯកឧត្តម ហេម វណ្ណឌី** រដ្ឋមន្ត្រី ក្រសួង ឧវបន

ក្នុងនាមថ្នាក់ដឹកនាំក្រសួង ឧវបន **ឯកឧត្តមរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ និងបុគ្គលិកសមាគម រួមទាំងសមាជិក សមាជិកាទាំងអស់ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។ សមិទ្ធផលដែលសម្រេចបានរបស់សមាគម បានរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងចូលរួមឆ្លើយតបនូវតម្រូវការរបស់ប្រជាជនក្នុងការទទួលបានទឹកស្អាតប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងលើកកម្ពស់ជីវភាព និងសុខភាព។ **ឯកឧត្តមរដ្ឋមន្ត្រី** បានបង្ហាញនូវសេចក្តីសប្បាយរីករាយ ដោយឃើញវិស័យឯកជនបានចូលរួមចំណែកយ៉ាងសកម្ម

ជាមួយ វិស័យសាធារណៈក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលផ្តោតលើវិស័យអាទិភាពគន្លឹះចំនួន ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា** ដែលវិស័យផ្គត់ផ្គង់ទឹកស្អាតនេះ ស្ថិតក្នុងចំណុចអាទិភាពទី៣។

**ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានលើកឡើងពីកិច្ចសហប្រតិបត្តិការរបស់ក្រសួង ឧវបន ជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធនាពេលកន្លងមក និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ឧវបន ក្នុងការជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងរដ្ឋាករទឹកសាធារណៈ ដែលទើបប្រែក្លាយជាសហគ្រាសសាធារណៈ ការពង្រឹងធនធានមនុស្សក្នុងវិស័យទឹកស្អាត និងការរៀបចំមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាតជាដើម។ ទន្ទឹមនឹងនោះ ក្រសួងក៏ចង់ឃើញប្រតិបត្តិករទឹកស្អាតឯកជន មានការពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការដឹកនាំ ការគ្រប់គ្រងអាជីវកម្ម បង្កើនភាពជាអ្នកដឹកនាំ ភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់ក្នុងការពង្រីក និងពង្រឹងសេវាកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងអាជ្ញាបណ្ណរបស់ខ្លួន ដោយឈរលើលក្ខខណ្ឌគោលទាំង៤ គឺការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយ **គុណភាព សុវត្ថិភាព និរន្តរភាព** និង **ថ្លៃសមរម្យ**។ ជាចុងក្រោយ **ឯកឧត្តមរដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធក្នុងការជួយគាំទ្រ និងជំរុញការផ្គត់ផ្គង់ទឹកស្អាតក្នុងប្រទេសកម្ពុជា ក្នុងការទទួលបានទឹកស្អាតទាំងអស់នៅឆ្នាំ២០៣០ និងបានជម្រាបជូនអង្គសន្និបាតអំពីកំណែទម្រង់ និងវិធានការមួយចំនួនដែលក្រសួងប្រកាន់យក ដើម្បីពង្រឹងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ដូចខាងក្រោម៖

- បង្កើត និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ជាពិសេសបទដ្ឋានគតិយុត្តដែលស្ថិតក្រោមច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត។ ក្នុងនោះសេចក្តីព្រាងអនុក្រឹត្យស្តីពី លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវបានកែសម្រួលបញ្ចប់ និងត្រៀមបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីបន្តនីតិវិធីស្នើសុំការអនុម័ត។
- គណៈកម្មាធិការវាយតម្លៃពាក្យស្នើសុំប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត (ឬអាជ្ញាបណ្ណ) ត្រូវបានកែសម្រួលឡើងវិញ។ ការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនឹងមិនត្រូវបានលើកទឹកចិត្តឱ្យបង្កើតចំនួនបន្ថែមច្រើននោះទេ ហើយនឹងត្រូវពិនិត្យឱ្យបានហ្មត់ចត់ទៅតាមករណីនីមួយៗនៅទីតាំងចាំបាច់បំផុត។
- ពង្រឹងប្រសិទ្ធភាពការងារជាអាទិភាព ជាជាងពង្រីកយកបរិមាណ។ ក្រសួងចាំបាច់ត្រូវបន្ថយល្បឿននៃការផ្តល់អាជ្ញាបណ្ណថ្មីៗ ដែលពុំបានរួមចំណែកផ្តល់ដំណោះស្រាយជាយុទ្ធសាស្ត្រគ្មាននិរន្តរភាព និងអាចបង្កជាផលវិបាកយូរអង្វែងទៅវិញ។ ក្រសួងនឹងចុះត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពធុរកិច្ចជាក់ស្តែងរបស់ប្រតិបត្តិករទូទាំងប្រទេស។
- ក្រសួងចាត់ទុកប្រតិបត្តិករឯកជនជាដៃគូយុទ្ធសាស្ត្រ ហើយរំពឹងថានឹងទទួលបានមកវិញនូវការទទួលខុសត្រូវ គណនេយ្យភាព តម្លាភាព និងគាំទ្រក្នុងការអនុវត្តច្បាប់បទដ្ឋានគតិយុត្ត។
- បង្កើនប្រសិទ្ធភាពការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករឯកជន ដោយផ្តោតលើចីរភាព និងគុណភាពទឹក តាមរយៈការជំរុញលើកទឹកចិត្តឱ្យមានការចែកចាយបន្តជាលក្ខណៈលក់ដុំរវាងរដ្ឋាករទឹកសាធារណៈដែលនៅមានសមត្ថភាពផ្គត់ផ្គង់ និងប្រតិបត្តិករឯកជន ឬរវាងប្រតិបត្តិករឯកជន និងប្រតិបត្តិករឯកជន។ ជាក់ស្តែងអនុស្សរណៈនៃការយោគយល់គ្នាលើការ

លក់ដុំ ត្រូវបានធ្វើរួចរាល់ចំនួន ២ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤កន្លងទៅនេះ។

- អនុស្សរណៈនៃការយោគយល់គ្នារវាងអតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ កាលពីឆ្នាំ២០០៥ ក៏នឹងត្រូវពិនិត្យ និងកែសម្រួលឡើងវិញ។
- បញ្ហាប្រភពទឹកក៏ជាបញ្ហាប្រឈមមួយសម្រាប់អ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត។ ក្រសួងនឹងសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងធនធានទឹក និងឧតុនិយម ដើម្បីបង្កើតយន្តការសម្របសម្រួលក្នុងការផ្តល់ និងថែរក្សាប្រភពទឹកឆៅសំដៅធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត។
- ក្រសួងបានចេញលិខិតទៅស្ថាប័នពាក់ព័ន្ធចំនួន ៦ លើបញ្ហាផលប៉ះពាល់ពីការជួសជុល កែលម្អ និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា មកលើបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងបានចម្លងជូនដល់សមាគមផងដែរ។ ក្រសួងកំពុងធ្វើការជាមួយក្រសួងពាក់ព័ន្ធដើម្បីកាត់បន្ថយផលប៉ះពាល់ និងត្រៀមទុកជាមុនដើម្បីបញ្ចៀសផលប៉ះពាល់។

**ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានជូនពរឱ្យអង្គសន្និបាតដំណើរការទៅដោយរលូន និងទទួលបានជោគជ័យតាមការរំពឹងទុក និងស្នើឱ្យសមាសភាពក្រុមប្រឹក្សាភិបា ដែលនឹងជាប់ឆ្នោតថ្មីទទួលបានជ័យជំនះថ្មីៗធំធេងបន្ថែមទៀត និងស្នើឱ្យគ្រប់ប្រតិបត្តិករទាំងអស់ដែលធ្វើការលើវិស័យទឹកស្អាតចូលជាសមាជិកសមាគម។ ក្រសួងនឹងបន្តគាំទ្រ និងលើកទឹកចិត្តឱ្យមានការសហការបានល្អរវាងសមាគម និងអគ្គនាយកដ្ឋានទឹកស្អាត ដែលជាសេនាធិការរបស់ក្រសួងឧវបន។

### ង. ពិធីប្រគល់វត្ថុអនុស្សាវរីយ៍ និងថតរូបអនុស្សាវរីយ៍

បន្ទាប់ពីថ្លែងសន្ទរកថាបើកកម្មវិធី **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលប្រគល់វត្ថុអនុស្សាវរីយ៍ដល់ថ្នាក់ដឹកនាំក្រសួង ឧវបន និងក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងមានការថតរូបអនុស្សាវរីយ៍ជុំគ្នាជាមួយគណៈអធិបតី និងអ្នកចូលរួមក្នុងអង្គសន្និបាតទាំងអស់។ ជាកិច្ចបន្ទាប់ **ឯកឧត្តមរដ្ឋមន្ត្រី** ដោយមានការអមដំណើរដោយគណៈអធិបតី អង្គទូត ក្រុមប្រឹក្សាភិបាល និងដៃគូអភិវឌ្ឍន៍បានទស្សនាការតាំងពិព័រណ៍ផលិតផល និងសេវាកម្មក្នុងវិស័យស្អាត ដែលមានក្រុមហ៊ុនចូលរួមចំនួន ១៩។

## ៤.២. សមិទ្ធិផលក្រុមប្រឹក្សាភិបាលអាណត្តិដំបូង សម្រាប់នីតិបុគ្គល (២០២០-២០២៣)

លោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល បានធ្វើបទបង្ហាញពីសមិទ្ធិផលរបស់ក្រុមប្រឹក្សាភិបាលក្នុងអាណត្តិដំបូង សម្រាប់នីតិបុគ្គល ដោយលោកបានបង្ហាញនូវចំណុចគោលធំៗចំនួន ៤គឺ៖

- ការរៀបចំគោលនយោបាយនានាដើម្បីធានានិរន្តរភាពការងារ និងស្របតាមតម្រូវការរបស់ដៃគូអភិវឌ្ឍន៍ ព្រមទាំងការកែសម្រួលលក្ខន្តិកៈសមាគម ដើម្បីចុះបញ្ជីសមាគមឡើងវិញជាស្ថាប័ននីតិបុគ្គល នៅក្រសួងមហាផ្ទៃនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១។
- ការពង្រឹងទំនាក់ទំនងជាមួយដៃគូទាំងក្នុង និងក្រៅប្រទេស តាមរយៈការចុះអនុស្សរណៈយោគយល់គ្នាជាមួយស្ថាប័នរាជរដ្ឋាភិបាល និងដៃគូជាតិ និងអន្តរជាតិ រួមទាំងការចូលរួមក្នុងសិក្ខាសាលា វេទិកា និងទស្សនកិច្ចសិក្សាក្នុងប្រទេស និងអន្តរជាតិ។
- ភាពជាតំណាងឱ្យសមាជិក តាមរយៈការរៀបចំសន្និបាតប្រចាំឆ្នាំ ការរៀបចំសន្និសីទ និង

ពិព័រណ៍ទឹក សិក្ខាសាលាផ្សព្វផ្សាយ កិច្ចប្រជុំថ្នាក់តំបន់ជាមួយសមាជិក និងការសម្របសម្រួល និងដោះស្រាយជម្លោះ និងបណ្តឹងនានារបស់សមាជិក។

- ការចូលរួមការងារសង្គម តាមរយៈការរៃអង្គាសថវិកាបរិច្ចាគដល់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ ការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ ការបរិច្ចាគថវិកាជូនមូលនិធិគន្ធបុប្ផាកម្ពុជា និងការរៃអង្គាសប្រាក់តាមគោលការណ៍ស្ម័គ្រចិត្ត ជូនដល់កងទ័ពឈរជើងការពារអធិបតេយ្យភាព និងបូរណភាពទឹកដីកម្ពុជា។

លោកក៏បានបញ្ជាក់បន្ថែមថា រាល់ការសម្រេចការងារអ្វីមួយរបស់សមាគមនាពេលកន្លងមក គឺធ្វើឡើងតាមរយៈការពិភាក្សារួមជាមួយសមាជិកក្រុមប្រឹក្សាភិបាល ដោយឈរលើគោលការណ៍គិតពីប្រយោជន៍សមាគមជាធំ។

## ៤.៣. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលអាណត្តិទី២ សម្រាប់នីតិបុគ្គល (២០២៤-២០២៧)

លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម បានបង្ហាញពីនីតិវិធី និងលក្ខខណ្ឌនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល អាណត្តិទី២ សម្រាប់នីតិបុគ្គល រួមមាន៖

- សមាជិកអាជីពមួយមានសិទ្ធិបោះឆ្នោតបានមួយសំឡេង (យោងលក្ខន្តិកៈ ប្រការ ៩ អំពីសមាជិកភាព)
- ក្រដាសឆ្នោតមួយអាចគូសជ្រើសរើសសមាជិកក្រុមប្រឹក្សាបាលដែលខ្លួនពេញចិត្តបានចំនួន ៩នាក់ (បើតិចជាង ៩នាក់ អាចយកជាការបាន តែបើលើសពី ៩នាក់ ចាត់ទុកជាមោឃៈ)
- ក្នុងសន្លឹកឆ្នោតអាចប្រើប្រាស់សញ្ញា (✓ ឬ x ឬ ០) ដើម្បីជ្រើសរើសនៅក្នុងប្រអប់ឈ្មោះបេក្ខជននីមួយៗ
- រាល់ការសម្រេចរបស់សន្និបាតមានតម្លៃទៅបាន លុះត្រាតែមានការអនុម័តដោយសំឡេង៥០% បូក១ នៃចំនួនសមាជិកអាជីព
- កូរ៉ុមរបស់សន្និបាតតម្រូវឱ្យមានវត្តមានសមាជិកអាជីពលើសពី២/៣
- អាចមានសិទ្ធិសុំដូរសន្លឹកឆ្នោតតែម្តងគត់ ប្រសិនបើខុស
- សន្លឹកឆ្នោតនីមួយៗត្រូវមានត្រារបស់សមាគម
- ការរាប់សន្លឹកឆ្នោតធ្វើឡើងចំពោះតែសន្លឹកឆ្នោតបានការប៉ុណ្ណោះ
- បេក្ខជនជាប់ឆ្នោតត្រូវមានសំឡេងច្រើនជាងគេ និងតាមលំដាប់ពីធំទៅតូច
- សមាជិកក្រុមប្រឹក្សាភិបាលជាប់ឆ្នោតត្រូវមានសមាជិកមកពីនីតិបុគ្គលយ៉ាងតិច ៥០% បូក១
- បេក្ខជនដែលជាប់ជាប្រធានត្រូវមានសំឡេងគាំទ្រច្រើនជាងគេ និងអនុប្រធានត្រូវមានសំឡេងច្រើនបន្ទាប់
- ហេរញ្ញិកនឹងត្រូវជ្រើសរើសតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាភិបាលជាប់ឆ្នោតអាណត្តិថ្មី។

ក្នុងនោះគណៈកម្មការបោះឆ្នោតត្រូវបានជ្រើសរើសពីសមាជិក និងបុគ្គលិកសមាគម ដែលមានចំនួន ៧នាក់ រួមមាន៖

- លោក ផុន សុគន្ធ សមាជិក
- លោក ខិញ តៃវេង សមាជិក
- លោក ឡុង ភារម្យ សមាជិក
- លោក ហុង គឹមលី ប្រធានផ្នែកទំនាក់ទំនង នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- លោក ជ្រិន ផាត់ វិស្វករជំនាញជាន់ខ្ពស់ទឹកស្អាត នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- លោក ឯម សារ៉ុម មន្ត្រីផ្នែកទំនាក់ទំនង នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- លោក លឹម មិញ នាយកប្រតិបត្តិ នៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

មុននឹងធ្វើការបោះឆ្នោត បេក្ខជនទាំងអស់ត្រូវបានអញ្ជើញឱ្យឡើងមកបង្ហាញពីប្រវត្តិរូប និងឆន្ទៈរបស់ខ្លួនក្នុងការក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលដែលបេក្ខជនសរុបមានចំនួន ១៣រូប ដូចខាងក្រោម៖

1. លោក **ជា សំបូរ៖** ជាអ្នកគ្រប់គ្រងទូទៅ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតអង្គតាសោម ខេត្តតាកែវ។ លោកមានបំណងចង់ជួយសមាជិកឱ្យរីកចំរើន និងពង្រឹងសមត្ថភាពសមាគមបន្ថែម ដើម្បីជាបង្អែកដល់សមាជិក។
2. លោក **ចាន់ ថានី៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបរហ៊ុយ ខេត្តប៉ៃលិន។ លោកមានបំណងចង់ឃើញសមាគមមានភាពរឹងមុំ និងរីកចម្រើន។
3. លោក មួង **ដារ៉ាវី៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតគគ្រួស ខេត្តកំពង់ស្ពឺ។ លោកមានបំណងចង់ជួយលើកកម្ពស់វិស័យទឹកស្អាតនៅកម្ពុជា។
4. លោកស្រី **ហាក់ សេងថា៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់កុង ខេត្តកណ្ដាល។ លោកស្រីមានបំណងចង់លើកកម្ពស់ប្រតិបត្តិករជាស្ត្រី និងចង់ឃើញប្រជាជនកម្ពុជាមានទឹកស្អាតប្រើប្រាស់ប្រកបដោយគុណភាព សុវត្ថិភាព និងនិរន្តរភាព។
5. លោក **ហម ងួន៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង ខេត្តកណ្ដាល។ លោកមានបំណងចង់ជួយសមាជិកឱ្យមានភាពរីកចម្រើនក្នុងអាជីវកម្ម តាមលទ្ធភាពដែលខ្លួនមាន។
6. លោកស្រី **យ៉ាន ធីតា៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសូទ្រនិគម ខេត្តសៀមរាប។ លោកស្រីមានបំណងចង់ជួយសមាគមឱ្យកាន់តែរីកចម្រើន និងចែករំលែកបទពិសោធន៍ល្អ ដើម្បីលើកកម្ពស់វិស័យទឹកស្អាតកម្ពុជា។
7. លោកវេជ្ជបណ្ឌិត **វី ខេមឫទ្ធិ៖** ជានាយកអភិវឌ្ឍន៍អាជីវកម្មរបស់ក្រុមហ៊ុន ខ្មែរ វ៉ដើរ ស៊ីបផ្លាយ ហូលឌីង ខូ អិលធីឌី។ លោកមានបំណងចង់ចូលរួមជួយលើកកម្ពស់ការងាររបស់សមាគម និងទាក់ទាញទុនវិនិយោគពីបរទេស ក៏ដូចជាការតស៊ូមតិជាមួយអ្នកពាក់ព័ន្ធក្នុងការលើកកម្ពស់វិស័យទឹកស្អាត។
8. លោកស្រី **ស៊ីម សៀមនី៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ ខេត្តកំពង់ចាម។ លោកស្រីមានបំណងចង់ជួយសមាគមឱ្យកាន់តែរីកចម្រើន តាមរយៈការជួយដោះស្រាយបញ្ហារបស់សមាជិក និងលើកកម្ពស់វិស័យទឹកស្អាតនៅកម្ពុជា។
9. លោក **ហៀក អេងឡាយ៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំចាយមារ ខេត្តព្រៃវែង។ លោកមានបំណងចង់ពង្រឹងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឱ្យនិរន្តរភាព និងជួយសមាគមរីកចម្រើនដើម្បី

បន្តជួយសមាជិក និងលើកស្ទួយវិស័យទឹកស្អាតឱ្យមានការរីកចម្រើន តាមរយៈការប្រមូលផ្តុំនូវចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ។

10. លោក **សៀវ ហួត៖** ជាអ្នកគ្រប់គ្រងទូទៅ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយរមៀត ខេត្តកណ្ដាល។ លោកមានបំណងចង់ជួយសមាគមរីកចម្រើន និងរឹងមាំក្នុងការជួយអាជីវករឱ្យរីកចំរើនទាំងអស់គ្នា ហើយប្រជាជនអាចទទួលបានទឹកស្អាតមានគុណភាព និងសុវត្ថិភាព។
11. លោក **ឡេង ខៀវ៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតឡេង ខៀវ ព្រែកអំបិល ខេត្តកណ្ដាល។ លោកមានបំណងចង់ជួយសមាជិកឱ្យរីកចំរើន ជាពិសេសអាជីវករដែលមិនមានលទ្ធភាព។
12. លោក **លាង បញ្ញា៖** ជាអ្នកគ្រប់គ្រងទូទៅនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រែកតាមាក់ ខេត្តកណ្ដាល។ លោកមានបំណងចង់ជួយផ្តល់ចំណេះដឹងបច្ចេកទេស និងចំណេះដឹងថ្មីៗជូនសមាជិក និងជួយដោះស្រាយបញ្ហារបស់សមាគម។
13. លោក **សៀ សេងហ៊ាប៖** ជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបែកចាន ខេត្តកណ្ដាល។ លោកមានបំណងចង់ជួយពង្រឹងសមាគមឱ្យមានភាពរឹងមាំតាមរយៈការស្វែងរកដៃគូអភិវឌ្ឍន៍ និងដៃគូដែលផ្តល់កម្ចីមានរយៈការស្វែងរកដៃគូអភិវឌ្ឍន៍ និងដៃគូដែលផ្តល់កម្ចីមានរយៈពេលវែងជូនដល់សមាជិក ពង្រឹងសមាគមក្នុងការតស៊ូមតិ និងពង្រឹងសាមគ្គីភាពក្នុងវិស័យទឹកស្អាត។

ក្នុងដំណើរការនៃការបោះឆ្នោត គណៈកម្មការបោះឆ្នោតបានប្រកាសឈ្មោះសមាជិកដែលមានសិទ្ធិបោះឆ្នោត ឡើងមកយក និងគូសសន្លឹកឆ្នោតដោយសម្ងាត់ដាក់ចូលក្នុងធុងប្រអប់ឆ្នោត។ នៅខណៈនោះគណៈកម្មការបោះឆ្នោតក៏បានលើកបង្ហាញធុងប្រអប់ឆ្នោតទទេស្អាត ជូនដល់អង្គពិធីទាំងមូលផងដែរ។

## **លទ្ធផលនៃការបោះឆ្នោត**

ក្នុងចំណោមអ្នកចូលរួម ៤១៥នាក់ មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតជាសមាជិកអាជីពចំនួន ១៩០ស្ថានីយ ស្ថិតក្នុងចំណោមសមាជិកអាជីពសរុបចំនួន ២៧១ស្ថានីយ ដែលស្មើនឹង ៧០% នៃសមាជិកអាជីពដែលមានសិទ្ធិបោះឆ្នោត។ ចំនួននេះ ធ្វើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលអាណត្តិទី២ សម្រាប់នីតិបុគ្គល ឆ្នាំ២០២៤-២០២៧ អាចប្រព្រឹត្តទៅបានស្របទៅតាមលក្ខន្តិកៈ ដោយសារតែសមាជិកអាជីពដែលបានចូលរួមចំនួនលើស ២ភាគ៣។

បន្ទាប់មក គណៈកម្មការបោះឆ្នោត បានហៅឈ្មោះសមាជិកអាជីពដែលជាអង្គបោះឆ្នោត មកទទួលសន្លឹកឆ្នោត និងបានធ្វើការបោះឆ្នោត ដោយប្រើប្រាស់សិទ្ធិស្វ័យសម្រេចស្របតាមឆន្ទៈឯករាជ្យរបស់ខ្លួនយ៉ាងពេញលេញ។

លទ្ធផលនៃការបោះឆ្នោតបានបង្ហាញថា៖

- លេខរៀងទី១ គឺលោក **ឡេង ខៀវ** ដោយទទួលបានសំឡេងឆ្នោតគាំទ្រ ១៤៣សំឡេង ច្រើនជាងគេ។
- អ្នកទទួលបានសំឡេងឆ្នោតគាំទ្រលេខរៀងទី២ បានទៅលើ លោកស្រី **ស៊ឹម សៀមនី** ដោយបានទទួលសំឡេងឆ្នោត ១១៩សំឡេង។

ដូច្នេះ លោក **ឡេង ខៀវ** នឹងក្លាយជាប្រធានក្រុមប្រឹក្សាភិបាល ហើយលោកស្រី **ស៊ីម សៀមនី** នឹងក្លាយជាអនុប្រធានក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិទី២ សម្រាប់នីតិបុគ្គល ឆ្នាំ២០២៤-២០២៧។

ព័ត៌មានលម្អិតពីចំនួនសន្លឹកឆ្នោត មានបង្ហាញក្នុងតារាងទី១ ខាងក្រោម៖

**តារាងទី១៖** លទ្ធផលនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះបេក្ខជន | ចំនួនសន្លឹកឆ្នោត | លេខលំដាប់ |
|---|---|---|---|
| ១ | លោក ជា សំបូរ | ៩៥ | ៨ |
| ២ | ចាន់ ថានី | ៩៥ | ៨ |
| ៣ | មួង ដារ៉ាវី | ៧២ | ១១ |
| ៤ | ហាក់ សេងថា | ៥៦ | ១៣ |
| ៥ | ហម ងួន | ១០៨ | ៤ |
| ៦ | យ៉ាន ធីតា | ១០៣ | ៥ |
| ៧ | វី ខេមឬទ្ធិ | ៦៨ | ១២ |
| **៨** | **ស៊ីម សៀមនី** | **១១៩** | **២** |
| ៩ | ហៀក អេងឡាយ | ៨០ | ១០ |
| ១០ | សៀវ ហួត | ១០០ | ៦ |
| **១១** | **ឡេង ខៀវ** | **១៤៣** | **១** |
| ១២ | លាង បញ្ញា | ៩៨ | ៧ |
| ១៣ | សៀ សេងហ៊ាប | ១១០ | ៣ |

ជាកិច្ចបន្ទាប់ គណៈកម្មការបោះឆ្នោតបានរាប់ឡើងវិញ និងរៀបចំទុកដាក់សន្លឹកឆ្នោតដែលបានបោះរួចក្នុងធុងប្រអប់ឆ្នោត និងបិទភ្ជិតធុងប្រអប់ឆ្នោតអមដោយហត្ថលេខាទទួលខុសត្រូវ ដើម្បីទុកជាឯកសារត្រួតពិនិត្យផ្ទៀងផ្ទាត់តាមការចាំបាច់។

## ៤.៤. បទបង្ហាញរបស់ដៃគូពាក់ព័ន្ធ

### ក. បទបង្ហាញរបស់អង្គការ Water.org

លោក **Pieter Tobing** តំណាងអង្គការ **Water.org** បានធ្វើបទបង្ហាញពីគម្រោងការងាររបស់អង្គការ **Water.org** និង **Water Equity** ដែលស្ថាប័នទាំងពីរនេះគឺជាដៃគូហិរញ្ញវត្ថុ/វិនិយោគលើការផ្តល់សេវាប្រឹក្សាយោបល់ដើម្បីគាំទ្រដល់ការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការពង្រឹងការវិនិយោគលើផលប៉ះពាល់ និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ កន្លងមកអង្គការ **Water.org** ក៏បានធ្វើការជាមួយរដ្ឋាភិបាលលើការកសាងលិខិតបទដ្ឋានគតិយុត្តិនានា និងផ្តល់ប្រឹក្សាយោបល់លើការវិនិយោគក្នុងវិស័យទឹកស្អាត និងអនាម័យ ការសិក្សាហេដ្ឋារចនាសម្ព័ន្ធ និងចូលរួមទុនវិនិយោគផងដែរ។ ទន្ទឹមនឹងនោះ អង្គការ Water Equity ធ្វើការលើជំនួយបច្ចេកទេសក្នុងការរៀបចំគម្រោង និងពង្រឹងក្រុមហ៊ុនដែលមានស្រាប់។ អង្គការក៏ធ្វើការផ្ទាល់លើការវិនិយោគលើទឹកស្អាត ប្រភពទឹក ប្រព្រឹត្តកម្មទឹក

ចែកចាយទឹក ការប្រមូលនិងសម្អាតទឹកកខ្វក់ និងការប្រើប្រាស់ទឹកកខ្វក់ឡើងវិញ។ ប៉ុន្តែអង្គការ នេះមិនធ្វើដោយខ្លួនឯងទេ គឺធ្វើការជាមួយដៃគូ និងជួយជាបច្ចេកទេសដល់ក្រុមហ៊ុនជាដៃគូ។ គម្រោងដែលអង្គការនេះវិនិយោគមានទំហំពីតូចដល់មធ្យម ដែលទំហំវិនិយោគមានរហូតដល់ ២០០លានដុល្លារ ក្នុងទម្រង់ភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈ និងរវាងឯកជននិងឯកជន។ ក្នុងនោះ កញ្ចប់វិនិយោគនីមួយៗរបស់អង្គការ មានទំហំរហូតដល់ ២០លានដុល្លារ ដែលកញ្ចប់វិនិយោគនីមួយៗមានរយៈពេលចន្លោះពី៥ឆ្នាំ ទៅ ៧ឆ្នាំ។ ការចូលទុនវិនិយោគនេះគ្រាន់តែជាផ្នែកតូចមួយនៃការវិនិយោគរួម អង្គការមិនមានបំណងយកគម្រោងវិនិយោគមកគ្រប់គ្រងខ្លួនឯងឡើយ។ ទីផ្សារវិនិយោគរបស់អង្គការគឺនៅប្រទេសដែលមានប្រាក់ចំណូលទាប ដូចជា មិកស៊ិកកូ ប៉េរូ នីហ្សេរីយ៉ា ប្រេស៊ីល បង់ក្លាដេស ឥណ្ឌា កេនយ៉ា និងអាហ្វ្រិកខាងត្បូង។ ដោយឡែកនៅតំបន់អាស៊ី អាគ្នេយ៍មាន កម្ពុជា ហ្វីលីពីន និង ឥណ្ឌូនេស៊ី។

**ខ. បទបង្ហាញរបស់កម្មវិធី CAPRED**

**CAPRED** គឺជាគម្រោងអភិវឌ្ឍន៍ដែលទទួលបានជំនួយពីប្រទេសអូស្ត្រាលី មានទំហំទឹកប្រាក់ ៨៧ លានដុល្លារអូស្ត្រាលី សម្រាប់ឆ្នាំ២០២២-២០២៧ ដោយធ្វើការលើវិស័យកសិកម្ម កសិឧស្សាហកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ (រួមបញ្ចូលទាំងទឹកស្អាត និងថាមពលស្អាត)។ យុទ្ធសាស្ត្រធំៗរបស់គម្រោងគឺ បង្កើនហិរញ្ញវត្ថុវិស័យ ពង្រឹងសមត្ថភាពដល់ភាគីពាក់ព័ន្ធវិស័យ និងជំរុញការវិនិយោគ និងបង្កើតគំរូអាជីវកម្មថ្មីៗ។ ក្នុងវិស័យទឹកស្អាត គម្រោងបានសហការជាមួយក្រសួងឧវបន ដូចជា៖

- ការបង្កើតមូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត
- ផ្តល់ជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុ ដល់ប្រតិបត្តិករទឹកស្អាតឯកជន ចំនួន១៨ ដើម្បីពន្លឿនភាពទទួលបានទឹកស្អាតក្នុងខេត្ត កំពង់ធំ កំពង់ឆ្នាំង និងតាកែវ ដោយបន្តពីគម្រោង**3i**
- ជំរុញការវិនិយោគ និងបង្កើតគំរូអាជីវកម្មថ្មីៗ៖ សិក្សាគំរូអាជីវកម្មទឹកដុំសម្រាប់ជានាសន្តិសុខប្រភពទឹក ក្នុងនោះក៏ផ្តោតលើការប្រែប្រួលអាកាសធាតុផងដែរ។ ទន្ទឹមនឹងនោះ ក៏មានការសិក្សាលើការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ខ្នាតតូចក្នុងទីជនបទ សម្រាប់ដំណើរការនីតិវិធីប្រកាសប្រកួតប្រជែង ក្នុងខេត្តឧត្តរមានជ័យ សៀមរាប និងរតនៈគិរី ដោយច្របាច់ការផ្គត់ផ្គង់ទឹកស្អាតតូចៗទាំងនោះបញ្ចូលគ្នា។ ដោយឡែក ស្ថានីយទឹកស្អាតដែលកំពុងដំណើរការ និងមិនទាន់មានដំណើរការល្អ គម្រោងកំពុងសិក្សាលើការរួមបញ្ចូល **(Merger system)**
- ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត
- ពង្រឹងសមត្ថភាពរដ្ឋាករទឹកស្អាត
- ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដោយសហការជាមួយសមាគម
- រៀបចំ និងសិក្សាលើផែនការវិនិយោគក្នុងវិស័យទឹកស្អាត (**PIP**)។

ក្នុងនោះផងដែរ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួង ឧវបន បានផ្តល់អនុសាសន៍លើ **PIP**

ដោយគម្រោងគួរសិក្សាបន្ថែមពីស្ថានភាពភូមិ ដោយមានការដាក់ពណ៌ផ្សេងៗលើផែនទីនូវទីតាំងភូមិសាស្ត្រណាមួយទៅតាមប្រភេទនៃភូមិដែលមានសក្តានុពល និងមិនមានសក្តានុពល និងពិបាកស្វែងរកលទ្ធភាពក្នុងការតភ្ជាប់បណ្តាញទឹកស្អាតតាមបំពង់ (ឆ្ងាយ ដាច់ស្រយាល) ដើម្បីយើងអាចចាត់អាទិភាពភូមិដែលអាចបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតបានមុន ឬជំហានក្រោយ ជាបន្តបន្ទាប់។ **ឯកឧត្តម** ក៏បានកត់សម្គាល់ពីការលក់ទឹកដុំ ដែលអង្គការ **Water.org** និង **CAPRED** បាននិងកំពុងចូលរួមធ្វើការងារនេះ ហើយនេះក៏ជាចំណុចអាទិភាពមួយដែលក្រសួងចង់លើកទឹកចិត្តផងដែរ។ ដូច្នេះស្នើឱ្យ **CAPRED** ពិចារណាដាក់បញ្ចូលផែនការលក់ទឹកដុំនេះទៅក្នុងផែនទី **PIP** ផងដែរ។ ឧទាហរណ៍៖ តើតំបន់ទាំងនោះអាចយកទឹកពីប្រភពណា (ទន្លេ ស្ទឹង អាងស្តុកទឹក ឬប្រភពផ្សេងៗ) ទៅជួយផ្គត់ផ្គង់នៅកន្លែងផ្សេងដែលខ្វះប្រភពទឹក។ ជាក់ស្តែង រដ្ឋាករទឹកស្អាតភ្នំពេញបាននឹងកំពុងពង្រីកសមត្ថភាពផលិតទឹករបស់ខ្លួន មិនមែនសម្រាប់តែផ្គត់ផ្គង់ក្នុងរាជធានីភ្នំពេញប៉ុណ្ណោះទេ គឺត្រៀមសម្រាប់លក់ចែកចាយទៅតំបន់ក្បែរៗរាជធានីភ្នំពេញផងដែរ។

### គ. បទបង្ហាញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (LOLC)

លោក **ថុង រិទ្ធី** នាយកនាយកដ្ឋានអាយផេ និងអាជីវកម្មឌីជីថល ធ្វើបទបង្ហាញពីផលិតផលប្រាក់កម្ចី និងសេវាកម្មរបស់អិលអូអិលស៊ី។ ក្នុងនោះគ្រឹះស្ថានមានកញ្ចប់កម្ចីធំៗចំនួន៤៖

- កម្ចីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម
- កម្ចីទឹកស្អាត និងអនាម័យ មានទំហំទឹកប្រាក់ដល់ ៨០០០ដុល្លារ
- កម្ចីតាមតម្រូវការ ដល់អាជីវកម្ម ឬអ្នកផ្គត់ផ្គង់ទឹកស្អាត ក្នុងទំហំរហូតដល់១០ម៉ឺនដុល្លារ ក្នុងនោះអ្នកខ្ចីអាចធ្វើការខ្ចីតាមរយៈ **Mobile App**។ ហើយបើអ្នកខ្ចីបានទទួលការអនុម័តកម្ចីហើយ ការគិតការប្រាក់គឺតាមការដកប្រាក់មកប្រើប្រាស់ជាក់ស្តែងប៉ុណ្ណោះ។ ចំពោះការប្រាក់អាចមានការចរចារពិសេសទៅតាមប្រភេទនៃទ្រព្យបញ្ចាំ។

ក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **LOLC** ក៏មានសេវាផ្សេងៗ ដូចជា ប្រាក់កម្ចី កាតអេធីអឹមជាង ៤០០០ទីតាំង សេវាធនាគារចល័តអាយផេ និងផ្ទេរប្រាក់តាមរយៈ**Fast, RFT** និង **Bakong** និងតាមរយៈទូរស័ព្ទដៃ។

### ឃ. បទបង្ហាញរបស់មូលនិធិ Stone Family Foundation

លោក **ឈឹម ទិត្យគ្រឹស្នា** នាយកផ្នែកទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្មរបស់អង្គការហ្វ្រេដ បានធ្វើបទបង្ហាញពីគម្រោងសម្របសម្រួលហិរញ្ញប្បទាន អាស្រ័យលើប្រាក់ចំណូលសម្រាប់អាជីវករទឹកស្អាតឯកជននៅកម្ពុជា។ ដោយបច្ចុប្បន្ន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនភាគច្រើនជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា អាជីវកម្មស្ថិតក្នុងតំបន់ដាច់ស្រយាលទាមទារឱ្យមានការវិនិយោគខ្ពស់ ប៉ុន្តែទទួលបានចំណូលត្រឡប់មកវិញទាប ហិរញ្ញវត្ថុភាគច្រើនខ្ចីបានតែពីធនាគារ ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋមានការធ្លាក់ចុះក្នុងរដូវវស្សា ថ្លៃភ្ជាប់បណ្តាញដំបូងមានតម្លៃថ្លៃសម្រាប់គ្រួសារ គ្រួសារក្រីក្រមិនមានលទ្ធភាពបង់ថ្លៃភ្ជាប់បណ្តាញ និងមានការខូចខាតបំពង់ទឹកស្អាតនានា។ កម្ចីវិនិយោគពីធនាគារបានបង្កផលលំបាកដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដោយសារតែការកំណត់រយៈពេល

បង់ត្រឡប់មកធនាគារវិញខ្លីពេក តម្រូវឱ្យមានវត្ថុបញ្ចាំច្រើន កំណត់ទំហំនៃការបង់ត្រឡប់ដោយមិនបានគិតពីទំហំនៃប្រាក់ចំណេញ និងមានអត្រាការប្រាក់ខ្ពស់។ ហេតុដូច្នេះហើយ គម្រោងនេះត្រូវបានផ្តួចផ្តើមឡើងដោយផ្តល់នូវរយៈពេលកម្ចីរហូតដល់ ១២ឆ្នាំ ក្នុងអត្រាការប្រាក់ចាប់ពី ៧% ដល់ ៩% និងតម្រូវវត្ថុបញ្ចាំស្មើ ១០០% នៃកម្ចី ជាមួយនឹងការបង់ត្រឡប់គិតជាសមាមាត្រទៅនឹងប្រាក់ចំណូល និងមានការប្រែប្រួលរវាងរដូវប្រាំង និងវស្សា។ ក្នុងនោះ កញ្ចប់របស់គម្រោងផ្តោតលើ កម្ចីសម្រាប់វិនិយោគ កម្ចីសម្រាប់ធ្វើទុនបង្វិល ជំនួយបច្ចេកទេស បង្ហាត់បង្រៀននិងបង្វឹក ជំនួយជនក្រីក្រ និងជំនួយទីផ្សារ។ ចន្លោះពីឆ្នាំ២០១៨ ដល់ ២០២៣ គម្រោងបានផ្តល់កម្ចីសរុបជាង ១០ លានដុល្លារ ដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ២៧ លើគម្រោងចំនួន ៣៥។ ទន្ទឹមនឹងនោះ គម្រោងបានជួយធ្វើទីផ្សារដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដើម្បីពន្លឿនការភ្ជាប់សេវាទឹកស្អាត លើកកម្ពស់ការយល់ដឹងអំពីទឹកស្អាតដល់ប្រជាពលរដ្ឋ ផ្លាស់ប្តូរបែបផែននៃការប្រើប្រាស់ទឹក និងបង្កើនការប្រើប្រាស់ទឹក ដើម្បីបង្កើនចំណូលសម្រាប់អាជីវកម្មទឹកស្អាត។

### ៤.៥. សមិទ្ធផលការងារសមាគម ឆ្នាំ២០២៣ និងផែនការឆ្នាំ២០២៤

លោក **លឹម មិញ** នាយកប្រតិបត្តិសមាគមបានធ្វើបទបង្ហាញដោយសង្ខេបលើសមិទ្ធផលការងារសមាគមឆ្នាំ២០២៣ និងផែនការឆ្នាំ២០២៤ ដូចខាងក្រោម៖

- **សមាជិកភាព៖** បំណាច់ឆ្នាំ២០២៣ សមាជិកសមាគមមានការកើនឡើងដល់ ៣៤៣ ស្ថានីយ/ក្រុមហ៊ុន ដែលមានសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុប ៣០០ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាតចំនួន ៤៣។
- **អភិបាលកិច្ច៖** បានរៀបចំសន្និបាតប្រចាំឆ្នាំ កិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាល (សាមញ្ញ និងវិសាមញ្ញ) និងកិច្ចប្រជុំឆ្លុះបញ្ចាំងការងាររបស់សមាគម។
- **ការងារជាមួយសមាជិក៖** បានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ គាំទ្រ និងសម្របសម្រួលកិច្ចប្រជុំដោះស្រាយទំនាស់របស់សមាជិក និងផ្តល់ជំនួយបច្ចេកទេសដល់សមាជិក។
- **កម្មវិធីកសាងសមត្ថភាព៖** បានសហការជាមួយមន្ទីរឧវបន និងសាខាពន្ធដារខេត្តបាត់ដំបង និងខេត្តកណ្តាល រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។
- **ភាពជាតំណាង៖** បានបង្កើនកិច្ចសហការទាំងថ្នាក់ជាតិជាមួយក្រសួងពាក់ព័ន្ធ និងអន្តរជាតិតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ ពិព័រណ៌ វេទិកាទឹក និងទស្សនកិច្ចនានាទៅកាន់ប្រទេសជប៉ុន ថៃ វៀតណាម ឥណ្ឌូនេស៊ី និងអូស្ត្រាលី។
- **ភាពជាដៃគូ៖** បានចុះអនុស្សរណៈយោគយល់ជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។
- **ការផ្តល់សេវាកម្ម៖** បានផ្តល់សេវាគូសផែនទីបណ្តាញទឹកស្អាត និងសម្របសម្រួលការងារទឹកស្អាតផ្សេងៗជាមួយក្រុមហ៊ុនដៃគូ។

ក្រៅពីនេះ សមាគមក៏បានសហការអនុវត្តគម្រោងផ្សេងៗ ជាមួយអង្គការ និងដៃគូអភិវឌ្ឍន៍ ដូចជា អង្គការ **WaterAid** អង្គការ **Water.org** អង្គការ **Aide et Action** អង្គការ **EMW** និងសាកល

វិទ្យាល័យ បច្ចេកវិទ្យាស៊ីដនី (**UTS**)។

**៤.៦. ពិធីជូនប័ណ្ណសសើរដល់ក្រុមប្រឹក្សាភិបាលអាណត្តិទី៣**

**ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួងឧរបន បានផ្តល់កិត្តិយសប្រគល់ប័ណ្ណសរសើរជូនសមាជិកក្រុមប្រឹក្សាភិបាល ដែលផុតអាណត្តិចំនួន ៩រូប។

ក្នុងនោះផងដែរ លោក **លឹម មិញ** នាយកប្រតិបត្តិសមាគម ក៏បានប្រគល់ប័ណ្ណសរសើរដល់សមាជិកដែលបានបង់វិភាគទានប្រចាំឆ្នាំមកសមាគមទាន់ពេលវេលាចំនួន ៣ឆ្នាំជាប់គ្នា រួមមាន៖

- ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែកតាមាក់
- ក្រុមហ៊ុន ហ្វ្រាណាស៊ី
- ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អរិយក្សត្រ
- ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំពៅលូន
- ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែករាំង
- ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំខ្ចប
- តំណាងការិយាល័យក្រុមហ៊ុន **Fuji Electric Co., Ltd** នៅកម្ពុជា

**៤.៧. បូកសរុបលទ្ធផលនៃអង្គសន្និបាត**

លោក **ហុង គឹមលី** ប្រធានផ្នែកទំនាក់ទំនងរបស់សមាគម បានធ្វើការបូកសរុបលទ្ធផលនៃអង្គសន្និបាតរយៈពេលមួយថ្ងៃ ដែលសម្រេចបានប្រកបដោយផ្លែផ្កាដូចការរំពឹងទុក។ ក្នុងនោះ លោកបានលើកឡើងដោយសង្ខេបពីចំណាប់អារម្មណ៍របស់គណៈអធិបតីក្នុងពិធីបើកអង្គសន្និបាត បទបង្ហាញរបស់ប្រធានក្រុមប្រឹក្សាភិបាលសមាគម លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលអាណត្តិទី២ សម្រាប់នីតិបុគ្គល បទបង្ហាញរបស់ដៃគូអភិវឌ្ឍន៍និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លទ្ធផលការងារសមាគមឆ្នាំ២០២៣ ក៏ដូចជាការប្រគល់ប័ណ្ណសរសើរដល់ក្រុមប្រឹក្សាភិបាលផុតអាណត្តិ និងសមាជិកដែលបានបង់វិភាគទានប្រចាំឆ្នាំកំឡុងពេល ៣ឆ្នាំជាប់គ្នា។

**៤.៨. ពិធីផ្ទេរមុខតំណែងប្រធានក្រុមប្រឹក្សាភិបាល**

លោក **លឹម មិញ** នាយកប្រតិបត្តិ បានថ្លែងអំណរគុណដល់ក្រសួង ឧរបន ក្រសួងអភិវឌ្ឍន៍ជនបទ ដៃគូអភិវឌ្ឍន៍ (**Water.org** និង **CAPRED)** ដែលបានឧបត្ថម្ភធំ និងក្រុមហ៊ុន ១៩ផ្សេងទៀតដែលបានសហការឧបត្ថម្ភដល់ការរៀបចំសន្និបាតឆ្នាំនេះរួមមាន៖១).ក្រុមហ៊ុន ធី អ៊ី អឹម ខូអិលធីឌី (**TEM)** ២).ក្រុមហ៊ុនវ៉ធើមិច ថេកណឡជី(**Watermech**) ៣).**Representative Office of Fuji Electric Co., Ltd** ៤).សហគ្រាស អ៊ី-ផៅវ័រ ស៊ីស៊ីអិល(**E-Power)** ៥).អិកវ៉ធើរ ថេកណឡជី(**X-Water)** ៦).ធីស៊ីយូប៉ូលី អេធើប្រាយ(**TCU)** ៧).ក្រុមហ៊ុនភ្នំពេញប្លាស្ទិចប្រូដាក់(**Phnom Penh Plastic)** ៨).ក្រុមហ៊ុន ធីនីមិច(**Dhinimex)** ៩).ក្រុមហ៊ុន វ៉ធើរ ផាតនើរ (ខេមបូឌា) ឯ.ក ១០).(**Water Partners)** ១១).ក្រុមហ៊ុន ខេស៊ីអអាយ អ៊ិនធើណេសិនណល ខូអបភើរេសិន ឯ.ក (**KCRI)** ១២).ក្រុមហ៊ុន លេសសូ (ខេមបូឌា) ត្រេឌីង ឯ.ក (**LESSO)** ១៣). **Petram Design International** ១៤).ក្រុមហ៊ុន ឥន្ទនូ ខេមបូឌាត្រេឌីង ១៥).**GEOCRAFT Co.,Ltd** ១៦).**Foreign Trade Bank of**

**Cambodia** ១៧). ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា១៨). **Stone Family Foundation** ១៩).មីក្រូហិរញ្ញវត្ថុ **LOLC** ។

កម្មវិធីផ្ទេរមុខតំណែងដល់ប្រធានក្រុមប្រឹក្សាអាណត្តិថ្មី ត្រូវបានធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួងឧវបន។ ដោយសារប្រធានអាណត្តិចាស់ បានជាប់ឆ្នោតសម្រាប់អាណត្តិថ្មីបន្តទៀត សមាគមបានសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមរដ្ឋលេខាធិការ** ផ្តល់កិត្តិយសប្រគល់ញញួរតំណាងអាណត្តិរបស់សមាគមជូន **លោក ឡេង ខៀវ** បន្តជាប្រធានក្រុមប្រឹក្សាភិបាលអាណត្តិទី២ សម្រាប់នីតិបុគ្គល ឆ្នាំ២០២៤-២០២៧។

## ៤.៩. សុន្ទរកថាបិទអង្គសន្និបាតលើកទី១២

**ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួងឧវបន បានអញ្ជើញថ្លែងសុន្ទរកថាបិទកម្មវិធីអង្គសន្និបាតលើកទី១២។ ជាកិច្ចចាប់ផ្តើម **ឯកឧត្តម** បានអបអរសាទរនូវលទ្ធផលការងារជាផ្លែផ្ការបស់សមាគម និងជូនពរក្រុមប្រឹក្សាអាណត្តិថ្មីឱ្យអនុវត្តការងារប្រកបដោយភាពស្វាហាប់ ដើម្បីជួយដល់សមាជិក និងបន្តធ្វើជាដៃគូដ៏ល្អរបស់ក្រសួងឧវបន ព្រមទាំងជួយលើកកម្ពស់វិស័យទឹកស្អាតនៅកម្ពុជា។ **ឯកឧត្តម** ក៏បានស្នើឱ្យសមាគមដាក់បញ្ចូលនូវសុន្ទរកថា ក៏ដូចអនុសាសន៍របស់ **ឯកឧត្តមរដ្ឋមន្ត្រី** ក្នុងពិធីបើកសន្និបាត ទៅក្នុងកម្រងឯកសាររបស់សមាគម និងចែកចាយដល់សមាជិកទាំងអស់តាមរយៈតេឡេក្រាមឱ្យបានជ្រាប។ **ឯកឧត្តម** ក៏បានជម្រាបជូនអង្គសន្និបាតនូវអនុសាសន៍ផ្តាំផ្ញើរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** និងផ្តល់ជាអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

- សុំឱ្យក្រុមប្រឹក្សាភិបាលអាណត្តិទី២ សម្រាប់នីតិបុគ្គល ព្រមទាំងសមាជិក និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនទាំងអស់ធ្វើម៉េចយ៉ាងណាប្រែក្លាយអាជ្ញាប័ណ្ណដែលក្រសួងប្រគល់ឱ្យយកទៅអនុវត្តឱ្យអស់លទ្ធភាព ដើម្បីបម្រើប្រជាពលរដ្ឋឱ្យបានពេញទំហឹង «មានន័យថាអាជ្ញាប័ណ្ណដែលយើងបានទទួល ត្រូវតែមានការឆ្លើយតប និងបំពេញ ពង្រីកការផ្គត់ផ្គង់ទឹកស្អាតឱ្យអស់ពីលទ្ធភាព តាមតំបន់សេវាដែលយើងទទួលខុសត្រូវ។
- ករណីធ្វើមិនបាន ត្រូវផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានទឹកស្អាតដែលជាសេនាធិការរបស់ក្រសួងឧវបន។ ក្នុងនោះ ក្រសួងក៏កំពុងត្រៀមរៀបចំនិយ័តករទឹកស្អាត ដើម្បីវាយតម្លៃលើសេវាផ្គត់ផ្គង់ទឹកស្អាតឯកជនទាំងអស់ និងជួយតម្រង់ទិសដើម្បីជានានូវភាពជោគជ័យ។ ដូច្នេះស្នើឱ្យប្រតិបត្តិករទាំងអស់ត្រូវផ្តល់ព័ត៌មានដើម្បីឱ្យរាជរដ្ឋាភិបាល ដែលមានក្រសួងឧវបន ជាសេនាធិការ ជួយរកអន្តរាគមន៍។
- **ឯកឧត្តម** បានរំលឹកថា កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ ក្នុងឱកាសប្រារព្ធពិធីបើកការដ្ឋានសាងសង់រោងចក្រទឹកស្អាត បាក់ខែងដំហាន១ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានមានប្រសាសន៍គាំទ្រក្នុងការប្រើពាក្យស្លោក «**ទឹកស្អាតសម្រាប់ទាំងអស់គ្នា**»ន័យនេះគឺគ្រប់គ្រាន់។ ទឹកស្អាតមិនមែនសម្រាប់តែបរិភោគទេ តែសម្រាប់បម្រើគោលដៅពហុបំណង ដូចជាសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាជន ,បម្រើវិស័យទេសចរណ៍ , សម្រាប់គម្រោងឧស្សាហកម្មសហគ្រាសធុនតូចនិងមធ្យម សិប្បកម្មកសិកម្ម។ល។ , ហើយទឹកស្អាតមិនមែនជាបន្ទុកតែរបស់ក្រសួង ឧវបន ដែរ គឺត្រូវការចូលរួមពីគ្រប់វិស័យ

រដ្ឋបាលថ្នាក់ក្រោមជាតិ ពីស្ថាប័នពាក់ព័ន្ធផ្សេងៗ ដូចជា ក្រសួងអភិវឌ្ឍជនបទ និងអង្គការដៃគូផ្សេងៗ។ ដូច្នេះ យើងខិតខំអនុវត្តដើម្បីបានជោគជ័យទាំងអស់គ្នា និងឆ្លើយតបទៅនឹងគោលដៅរបស់រាជរដ្ឋាភិបាល ហើយក៏ត្រូវការចូលរួមពីប្រតិបត្តិករឯកជនដែលបាននិងកំពុងចូលរួមប្រមាណ ៥០ភាគរយផងដែរ។

- ក្រសួងនឹងមានក្រុមការងារចុះត្រួតពិនិត្យវាយតម្លៃ ការផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស ដោយចាប់ពីខែមីនា ដល់ខែមិថុនា និងចេញជារបាការណ៍រួមមួយ។ ដូច្នេះ **ឯកឧត្តម** ក៏បានស្នើឱ្យកម្មវិធី **CAPRED** ចូលរួមសហការជួយលើការងារនេះជាមួយក្រសួង ដើម្បីកំណត់រកនូវបញ្ហា និងកិច្ចអន្តរាគមន៍។ ក្នុងនោះ ជំហររបស់ក្រសួងគឺអនុវត្តនយោបាយឈ្នះឈ្នះ ដើម្បីជួយស្រោចស្រង់ប្រតិបត្តិករទឹកស្អាតឯកជន។
- ក្រសួងនឹងបន្តគាំទ្រដល់សមាគម ក្នុងករណីក្រុមប្រឹក្សាភិបាលថ្មីត្រូវការកែសម្រួល ឬចុះអនុស្សារណៈយោគយល់ថ្មីជាមួយក្រសួង។
- យើងសង្ឃឹមថា ក្រុមប្រឹក្សាភិបាលអាណត្តិថ្មីរបស់សមាគម នឹងយកគោលការណ៍ច្បាប់មកពង្រឹងការអនុវត្ត និងបន្តសហការ គាំទ្រគ្នា។ ឆ្លៀតឱកាសនេះ ខ្ញុំសូមផ្តាំផ្ញើថា រាល់បញ្ហាដែលកើតមានឡើង គឺសមាគមត្រូវដាក់ចូលក្នុងវេទិកាពិភាក្សា ឬពិភាក្សាជាក្រុមតូចៗ ឬទទួលយកមកដោះស្រាយភ្លាមៗ ដោយមិនមែនរង់ចាំតែការប្រជុំធំ ឬសន្និបាតនោះទេ។ ពេលខ្លះ គេអាចជួបគ្នាដោះស្រាយបញ្ហាតាមតាមអនឡាញបាន។ សំឡេងរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតតែមួយ មិនអាចទៅរួចទេ ហើយក្រសួងក៏ពិបាកក្នុងការទទួលសំឡេង ២០០ទៅ៣០០នាក់ដែរ ដូច្នេះក្រសួងនឹងទទួលសំណូមពររបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតតាមរយៈក្រុមប្រឹក្សាភិបាលសមាគម ដែលជាតំណាងរបស់បងប្អូន។
- **ឯកឧត្តម** ក៏បានជម្រាបជូនអង្គសន្និបាត នូវកម្មវិធី ទិវាវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍របស់ក្រសួងថ្ងៃទី២៤-២៦ ខែមីនា ឆ្នាំ២០២៤ នៅកោះពេជ្រ ក្រោមអធិបតីភាព **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ផងដែរ។ ដូចនេះ សមាជិកសមាគមដែលមានបំណងចូលរួមតាំងបង្ហាញផលិតផល និងសេវាកម្មរបស់ខ្លួន អាចទំនាក់ទំនងមកអគ្គនាយកដ្ឋានទឹកស្អាត។
- ក្រសួងបានពិនិត្យឃើញថា ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតមួយចំនួនបានប្រើឈ្មោះជា «រដ្ឋាករទឹកស្អាត»។ ក្រសួងបានចេញគោលការណ៍ណែនាំ មិនឱ្យវិស័យឯកជនប្រើប្រាស់ពាក្យ «រដ្ឋាករទឹកស្អាត» នោះទេ។ ដូច្នេះ ស្នើកុំឱ្យមានការប្រើប្រាស់ឈ្មោះ រដ្ឋាករទឹកស្អាតទៀតដែលនាំឱ្យប្រជាជនមានការភាន់ច្រឡំ។ ប្រតិបត្តិករទឹកស្អាតឯកជនទាំងអស់អាចដាក់ឈ្មោះអាជីវកម្មរបស់ខ្លួន ដោយបន្ថែមពាក្យនៅក្នុងវង្វង់ក្រចកថា (ប្រតិបត្តិករទឹកស្អាតឯកជន) ដែលការអនុវត្តដូចនេះ មានរួចមកហើយជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន។
- ស្នើប្រតិបត្តិករទាំងអស់អនុវត្តឱ្យបាននូវលក្ខខណ្ឌចំនួន ៤ ដែលមានចែងក្នុងអាជ្ញាប័ណ្ណ គឺ **ទឹកមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។**
- អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន បានស្នើឱ្យប្រតិបត្តិករទាំងអស់បន្ថែមពាក្យស្លោកដែល

ទាក់ទងនឹងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ក្នុងនោះជាយោបល់ **ឯកឧត្តម** គឺយើងអាចធ្វើបាន ក៏ប៉ុន្តែស្នើឱ្យសមាគមជាអ្នកសម្រេចធ្វើបាន ឬមិនបាន។ ដោយសារវិក្កយបត្រទឹកស្អាតខ្លះបានបោះពុម្ពរួចរាល់ហើយ និងមិនអាចបោះចោលបាន ដូច្នេះ **ឯកឧត្តម** បានជូនជាយោបល់ ឱ្យធ្វើជាត្រាជ្រុងមួយដែលមានសរសេរពាក្យស្លោក សម្រាប់បោះត្រាលើវិក្កយបត្រដែលមានស្រាប់។ ធ្វើដូចនេះ យើងអាចសន្សំថវិកាលើវិក្កយបត្រដែលបានបោះពុម្ពរួច។ **ឯកឧត្តម** ក៏បានលើកនូវជម្រើសពាក្យស្លោកដែលមានខ្លឹមសារល្អ គឺ «**ប្រើគ្រឿងញៀនគឺបំផ្លាញខ្លួនឯង គ្រួសារ និងសង្គមជាតិ**»។ សមាគមអាចធ្វើការឆ្លើយតប លើការងារនេះនៅពេលក្រោយបាន។

- ជាចុងក្រោយ **ឯកឧត្តម** តាងនាមឱ្យស្រ្តួងឧវបន និងសហការី ក៏បានអបអរសាទរដល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលអាណត្តិទី២ សម្រាប់នីតិបុគ្គល ហើយសង្ឃឹមថាក្រុមប្រឹក្សាភិបាលនឹងកាន់តែមានពលានុភាព និង សមត្ថភាពក្នុងការអនុវត្តការងាររបស់សមាគមឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ជាពិសេស **ឯកឧត្តម** ក៏មានការសប្បាយរីករាយបន្ថែមទៀតដោយសារតែក្រុមប្រឹក្សាភិបាល អាណត្តិថ្មីនេះ មានសមាជិកជាស្ត្រីបន្ថែម១រូបទៀត លើសពីអាណត្តិមុន។ មុននឹងបញ្ចប់ **ឯកឧត្តម** បានជូនពរដល់ភ្ញៀវជាតិ អន្តរជាតិ និងសមាជិកសមាជិកាសមាគម ទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## ៤.១០. ពិធីទទួលទានអាហារសាមគ្គី

បន្ទាប់ពីកម្មវិធីបិទអង្គសន្និបាតលើកទី១២ អ្នកចូលរួមទាំងអស់បានអញ្ជើញចូលរួមពិធីពិសារអាហារសាមគ្គីជុំគ្នា ដើម្បីបង្កើនទំនាក់ទំនង ភាពស្និទ្ធស្នាល និងសាមគ្គីភាពរវាងគ្នា និងគ្នា។

សន្និបាតលើកទី១២ របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវបានបញ្ចប់នៅវេលាម៉ោង ៨.៣០យប់ នៅក្នុងថ្ងៃខែឆ្នាំដដែល ប្រកបដោយភាពជោគជ័យ សប្បាយរីករាយ និងស្និទ្ធស្នាលជាទីបំផុត។

ថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

**អ្នកធ្វើកំណត់ហេតុ**

**បានឃើញ និងឯកភាព**

**ប្រធាន**

**ឡេង ខៀវ**

**ប្រធានក្រុមប្រឹក្សាភិបាល**

**លឹម មិញ**

**នាយកប្រតិបត្តិ**